# ករណីសិក្សា

# ស្តីពីដំណើរការសម្របសម្រួលស្ត្រីធ្វើការក្នុងសេវាកម្សាន្ត

# ទទួលបានប័ណ្ណមូលនិធិសមធម៌ - គម្រោងសុខភាពបន្តពូជនិងសិទ្ធិ

# “ប័ណ្ណក្រីក្រ បានជួយសង្គ្រោះជីវិតខ្ញុំ”



នាង**ហ្សួន ណារ៉ែន** អាយុ៣៦ឆ្នាំ ជាស្ត្រីមេម៉ាយ មានទីកំណើតនៅភូមិ មហាសៀកក្រោម ឃុំមហាខ្ញូង ស្រុកកោះសូទិន ខេត្តកំពង់ចាម ដែលនាងបានផ្លាស់ទីលំនៅមករស់នៅទីក្រុងភ្នំពេញ និងកំពុងប្រកបរបរជាស្ត្រីម៉ាស្សាកោសជប់ និងស្នាក់នៅភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ បានរយៈពេល ១០ខែ។

នាង  បានប្រាប់មកក្រុមការងារថា  "មុខរបរខ្ញុំមិនសូវមានចំណូល(មួយអាទិត្យបានពីរទៅបីភ្ញៀវ)ចំពោះបញ្ហាក្នុងគ្រួសារខ្ញុំមានបំណុលជាមួយធនាគារ"។ នាង បានបន្តទៀតថា "ខ្ញុំមានជម្ងឺ គិសដៃស្បូនដំណាក់កាលកណ្តាល (ទី២) ដែលតម្រូវឱ្យវះកាត់ ប៉ុន្តែខ្ញុំមិនមានលទ្ធភាពទេ"។

នាង បានលើកឡើងថា "ខ្ញុំបានដឹងពត៌មានពីប័ណ្ណក្រីក្រពីខាងអ្នកគ្រូធ្វើការសមាគមនារី(អ្នកគ្រូអាវស) ដោយក្រុមអ្នកគ្រូពាក់អាវស  ដែលគាត់បានពន្យល់ណែនាំពីអត្ថប្រយោជន៍ប័ណ្ណសមធម៌(ក្រីក្រ)និងប័ណ្ណមូលនិធិសមធម៌សុខាភិបាល(ម.ស.ស) ដល់នាងខ្ញុំ ពេលគាត់ចុះមកអប់រំស្ត្រីនៅហាង"។

ជាមួយទឹកមុខញញឹម នាងណារ៉ែន បានបន្តបញ្ជាក់ពីមូលហេតុដែលនាងសម្រេចចិត្តធ្វើប័ណ្ណក្រីក្រ ពីព្រោះគាត់ពុំមានលិទ្ធភាពមើលជម្ងឺ ហើយនិងកំពុងខ្វះខាតខ្លាំងលើជីវភាពរស់នៅប្រចាំថ្ងៃ។ នាង បានចែករំលែកពីបទពិសោធន៍របស់នាង ក្នុងការស្នើសុំប័ណ្ណក្រីក្រ ក្រោមការសម្របសម្រួលពីក្រុមអ្នកអប់រំផ្ទាល់គម្រោងសុខភាពបន្តពូជនិងសិទ្ធិ និងអ្នកគ្រូខាងបណ្តាញស្ត្រី៖



- កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ នាងបានទៅជួបជាមួយមេភូមិនិងខាងសង្កាត់ ដែលនាងកំពុងស្នាក់នៅ ដោយភ្ជាប់ជាមួយឯកសារចាំបាច់មួយចំនួនដូចជាៈ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ច្បាប់ដើម លិខិតបញ្ជាក់ការស្នាក់នៅ និងវិក័យបត្រជួលផ្ទះពីម្ចាស់ផ្ទះជួល
- នៅរសៀលថ្ងៃដដែល នាងបានចូលសម្ភាសន៍ជាមួយក្រុមការងារខាងសង្កាត់ រួចនាងក៏ត្រឡប់ទៅផ្ទះវិញ
- នៅពេលយប់ថ្ងៃដដែល ខាងសង្កាត់ក៏បានទាក់ទងមកក្រុមអ្នកអប់រំផ្ទាល់គម្រោងសុខភាពបន្តពូជនិងសិទ្ធិ និងអ្នកគ្រូខាងបណ្តាញស្ត្រី ដើម្បីទៅទទួលប័ណ្ណក្រីក្រ
- នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ក្រុមការងារបានយកប័ណ្ណក្រីក្រទៅប្រគល់ជូន ណារ៉ែន។




នាងណារ៉ែន បានបញ្ជាក់ថា នាងទទួលបានប័ណ្ណក្រីក្រកម្រិត២ ដោយនាងបានបន្តទៀតថា "ខ្ញុំមានអារម្មណ៍ថាធូរចិត្ត សប្បាយចិត្តព្រោះបានទៅពិនិត្យជម្ងឺដោយមិនគិតប្រាក់។ លើសពីនេះ នាងបានបន្តថា "ប័ណ្ណក្រីក្រពិតជាមានអត្ថប្រយោជន៍ណាស់ ព្រោះនាងអាចអាចប្រើប័ណ្ណនេះទាំងគ្រួសារទៅពិនិត្យសុខភាពមិនគិតប្រាក់ហើយ។ ចំណែកខាងមន្ទីរពេទ្យ ក៏គេយកចិត្តទុកដាក់"

នាង បានប្រើប្រាស់ប័ណ្ណក្រីក្រនេះ ដើម្បីទទួលបានការវះកាត់ ដោយពុំមានតម្រូវឱ្យបង់ប្រាក់ថ្លៃព្យាបាលឡើយ។ ស្ថិតក្រោមការពិនិត្យ និងតាមដានស្ថានភាពសុខភាពពីគ្រូពេទ្យ នាងណារ៉ែន បានបញ្ចេញអារម្មណ៍រភើប និងសប្បាយរីករាយ ដោយនាងបានលើកឡើងថា "ខ្ញុំសូមអរគុណជាខ្លាំងដល់ខាងសមាគមនារី អ្នកគ្រូអាវសេ និងអ្នកគ្រូខាងបណ្ដាញដៃរបានជួយសម្របសម្រួលគាត់ ឱ្យទទួលបានប័ណ្ណក្រីក្រនេះ"

នាង ក៏បានសំណូមពរថា "អនាគតពេលប័ណ្ណផុតកំណត់ (អស់សុពលភាព) គាត់នឹងធ្វើការស្នើរសុំទៀត"។

រៀបរៀងដោយ លោក ទិត្យ ច័ន្ទគ្រីស្នា - អ្នកសម្របសម្រួលគម្រោងសុខភាពបន្តពូជនិងសិទ្ធិ

រូបថតដោយ ឡឹង ចន្ថា និងយ៉ាង បរមី៉ - អ្នកអប់រំផ្ទាល់គម្រោងសុខភាពបន្តពូជនិងសិទ្ធិ

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងកក់ក្តៅចំពោះមូលនិធិសហប្រជាជាតិដើម្បីប្រជាជន UNFPA សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ បណ្តាញថ្នាក់ជាតិស្ត្រីធ្វើការក្នុងសេវាកម្សាន្ត (NEWN) និងដៃគូរសហការសម្រាប់ការចូលរួមគាំទ្រការអនុវត្តគម្រោងសុខភាពបន្តពូជនិងសិទ្ធិ ។

ភ្នំពេញ ប្រទេសកម្ពុជា